City of Seattle

# សេចក្តីជូនដំណឹងអំពីការមិនរើសអើង

ទីក្រុងស៊ីតថល (ទីក្រុង) ធានាថា គ្មានបុគ្គលណានឹងត្រូវបានរើសអើងប្រឆាំងនឹងកម្មវិធីទីក្រុង និងសកម្មភាពនានាដែលផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ប្រភពដើមជនជាតិ សាសនា ភេទ អាយុ ឬពិការភាពឡើយដូចដែលបានផ្តល់ដោយចំណងជើង VI នៃ Civil Rights Act of 1964 (ច្បាប់សិទ្ធិស៊ីវិលនៃឆ្នាំ 1964), Civil Rights Restoration Act of 1987 (ច្បាប់ស្តារឡើងវិញសិទ្ធិស៊ីវិលនៃឆ្នាំ 1987) (P.L. 100.259), Age Discrimination Act of 1975 (ច្បាប់រើសអើងអាយុនៃឆ្នាំ 1975), ដូចបានធ្វើវិសោធនកម្ម និងចំណងជើង II នៃ American with Disabilities Act (ច្បាប់ជនជាតិអាមេរិកដែលមានពិការភាព)។
ទីក្រុងគោរពបន្ថែមទៀតតាមច្បាប់សិទ្ធិស៊ីវិលរដ្ឋ និងក្រុងបន្ថែម និងធានាថា គ្មាននរណាម្នាក់នឹងត្រូវបានរើសអើងក្នុងកម្មវិធី និងសកម្មភាបផ្សេងៗរបស់ខ្លួនឡើយ ផ្អែកលើទំនោរផ្លូវភេទ អត្តសញ្ញាណយេនឌ័រ ស្ថានភាពអាពាហ៍ពិពាហ៍ ស្ថានភាពឪពុកម្តាយ មនោគមវិជ្ជានយោបាយ ជំនឿ ពូជពង្ស ការចូលរួមក្នុងកម្មវិធីផ្តល់លំនៅដ្ឋាន Section 8 (ផ្នែក 8), ស្ថានភាពយោធា ឬស្ថានភាពអតីតយុទ្ធជន ឬដោយសារតែការបំបៅកូនដោយទឹកដោះនៅទីកន្លែងសាធារណៈរបស់ពួកគេ ដូចបានផ្តល់ដោយ Seattle Municipal Code (ក្រមទីក្រុងស៊ីតថល) 14.04, 14.06 និង 14.10។

បុគ្គលណាដែលមានអារម្មណ៍ថា ពួកគេត្រូវបានទទួលការរើសអើងដែលត្រូវបានការពារនៅក្រោមចំណងជើង VI ឬច្បាប់ដទៃ អាចដាក់បណ្តឹងជាមួយ Seattle Office for Civil Rights (ការិយាល័យសម្រាប់សិទ្ធិស៊ីវិលស៊ីតថល) បាន។

សម្រាប់ព័ត៌មានបន្ថែមស្តីពី City of Seattle Title VI program (កម្មវិធីចំណងជើង VI នៃទីក្រុងស៊ីតថល) ឬសម្រាប់ព័ត៌មានស្តីពីរបៀបដាក់បណ្តឹង សូមទូរស័ព្ទទៅ Seattle Office for Civil Rights (ការិយាល័យសម្រាប់សិទ្ធិស៊ីវិលស៊ីតថល) តាមលេខ (206) 684-4500, អ៊ីម៉ែល ocr_intake@seattle.gov, ចូលមើល www.seattle.gov/civilrights ឬមកដោយផ្ទាល់នៅ 810, Third Avenue, Suite 750, Seattle, WA 98104។ Seattle Office for Civil Rights គឺបើកពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ម៉ោង 8 ព្រឹក ដល់ 5 ល្ងាច។